គ.ជ.ប

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

# ព្រឹត្តិបត្រ

លេខ ១ ចេញផ្សាយថ្ងៃទី០៧ ខែមករា ឆ្នាំ២០១២

# គោលនយោបាយ

# គណបក្ស

# ក្នុងការឃោសនាបោះឆ្នោត

# ជ្រើសតាំងសមាជិកព្រឹទ្ធសភា

# នីតិកាលទី៣

# គណបក្ស សម រង្ស៊ី

## SAM RAINSY PARTY
## PARTI SAM RAINSY

**សីលធម៌ សច្ចធម៌ យុត្តិធម៌**

## វិធានការដោះស្រាយបញ្ហាបូរណភាពទឹកដី និងជីវភាពរស់នៅ របស់ប្រជាពលរដ្ឋ នៃរដ្ឋាភិបាល សម រង្ស៊ី



*លោកប្រធាន សម រង្ស៊ី សំណេះសំណាលជាមួយសកម្មជនគណបក្ស និងអ្នកគាំទ្រ*

### I_វិធានការដោះស្រាយបញ្ហាបូរណភាពទឹកដី

១_ទាមទារលុបចោលសន្ធិសញ្ញាព្រំដែនដែលរដ្ឋអំណាចសម័យមុនបានចុះហត្ថលេខាជាមួយប្រទេសវៀតណាម កាលពីឆ្នាំ១៩៧៩ ១៩៨២ ១៩៨៣ និង១៩៨៥ និងសន្ធិសញ្ញាព្រំដែនបំពេញបន្ថែមឆ្នាំ២០០៥ ដែលធ្វើអោយប្រទេសកម្ពុជាបាត់បង់ទឹកដីជាច្រើន ។ សន្ធិសញ្ញាទាំងនេះរំលោភកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១ ស្តីអំពីអធិបតេយ្យភាព ឯករាជភាព និងបូរណភាពទឹកដីប្រទេសកម្ពុជា ។

២_ស្នើកោះប្រជុំឡើងវិញ សន្និសីទទីក្រុងប៉ារីសស្តីពីសន្តិភាពនៅកម្ពុជាដើម្បីទាមទារអោយមានការគោរពត្រឹមត្រូវចំពោះកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១ ទាក់ទងទៅនឹងការធានាបូរណភាពទឹកដីប្រទេសកម្ពុជា ។

៣_ដិតដំខ្លះខ្នែងតាមគ្រប់មធ្យោបាយសន្តិវិធី ទាមទារជូនប្រទេសកម្ពុជាវិញ នូវទឹកដីដែលប្រទេសជិតខាងបានលួចយកដោយខុសច្បាប់ ។ តំរូវអោយប្រទេសជិតខាងគោរពព្រំដែនប្រទេសកម្ពុជា ដូចដែលពិភពលោកទាំងមូលបានទទួលស្គាល់នៅឆ្នាំ១៩៦៧-១៩៦៨ ក្នុងសម័យសង្គមរាស្ត្រនិយម ។

៤_តវ៉ាតាមផ្លូវទូតយ៉ាងម៉ឺងម៉ាត់បំផុត ចំពោះរាល់ការរំលោភដែនគោក ដែនទឹក និងដែនអាកាសរបស់ប្រទេសកម្ពុជាពីសំណាក់ប្រទេសជិតខាង ហើយលើកយកបញ្ហាព្រំដែននេះ អោយសហគមន៍អន្តរជាតិ និងអង្គការសហប្រជាជាតិជួយដោះស្រាយ ។ ផ្តល់បញ្ជាយ៉ាងច្បាស់លាស់ដល់យោធា និងប៉ូលីសនៅតាមព្រំដែនអោយការពារទឹកដីប្រទេសយើងយ៉ាងម៉ឺងម៉ាត់ ។

៥-អនុវត្តកម្មវិធីអភិវឌ្ឍន៍ជនបទ ដោយផ្តល់អាទិភាពពិសេសដល់តំបន់ជាប់ព្រំប្រទល់ដែន ។ ការកសាងផ្លូវថ្នល់ និងរាល់វិធានការ ដើម្បីលើកស្ទួយជីវភាពប្រជារាស្ត្រនៅតំបន់ព្រំដែន ជាផ្នែកមួយនៃការការពារបូរណភាពទឹកដី ។



*លោកប្រធាន សម រង្ស៊ី និងលោកស្រី មាស ស្រី ម្ចាស់ដីស្រែ ដែលអាជ្ញាធរយួនចុះបង្ខំលោកយក តាមរយៈការបោះបង្គោលព្រំដែន នៅឃុំសំរោង ស្រុកចន្ទ្រា ខេត្តស្វាយរៀង*

## II-ទិសដៅការលើកតម្កើងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ

### ១-ប្រជារាស្ត្រទូទៅ

_ប្រជារាស្ត្រតាមភូមិ ឃុំ និងសហគមន៍តាមមូលដ្ឋាន មានសិទ្ធិសម្រេចក្នុងការគ្រប់គ្រងដីធ្លី ព្រៃឈើ និងតំបន់នេសាទ ដោយសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីធានាការអភិវឌ្ឍន៍អោយបានយូរអង្វែង ដោយការពារទ្រព្យសម្បត្តិធម្មជាតិ និងបរិស្ថានអោយបានល្អត្រឹមត្រូវ ។

_ដោះស្រាយវិវាទដីធ្លីដែលមានសព្វថ្ងៃ រវាងអ្នកមានអំណាច និងប្រជារាស្ត្រតូចតាច ដោយជួយការពារសិទ្ធិស្របច្បាប់របស់ប្រជារាស្ត្រតូចតាច ដែលត្រូវបានអ្នកមានអំណាចរំលោភ ។

_បញ្ឈប់ការរឹបអូសយកដីធ្លីពីប្រជារាស្ត្រ និងការបណ្តេញប្រជារាស្ត្រពីដីធ្លី ដែលពួកគាត់បានរស់នៅយូរឆ្នាំមកហើយ ។ បើមានសំណើណាមួយអោយប្រជារាស្ត្រចាកចេញពីដីធ្លី ដែលពួកគាត់កំពុងតែរស់នៅ សំណើនោះត្រូវមានភ្ជាប់ជាមួយនូវសំណងដ៏សមរម្យ និងយុត្តិធម៌ជូនប្រជារាស្ត្រ ។ សំណងនោះអាចជាដីធ្លីនៅទីកន្លែងណាមួយទៀត មានលក្ខណៈប្រហាក់ប្រហែលដីធ្លីដើម ឬជាថវិកាមានចំនួនប្រហាក់ប្រហែលតម្លៃដីធ្លីដើម ។

_ពិនិត្យសើរើការរឹបអូសដីធ្លីរបស់ប្រជារាស្ត្រចាប់តាំងពីឆ្នាំ១៩៨៩ មកដល់សព្វថ្ងៃ ។ បើសិនជាការរឹបអូសនោះ ជាអំពើខុសច្បាប់ និងអយុត្តិធម៌ ដីធ្លីនោះត្រូវប្រគល់សងជូនម្ចាស់ដើមស្របច្បាប់វិញ ។

_បញ្ឈប់ការរុះរើផ្ទះសំបែងប្រជារាស្ត្រ និងការបណ្តេញប្រជារាស្ត្រពីផ្ទះសំបែងដែលពួកគាត់បានរស់នៅយូរឆ្នាំមកហើយ ទោះជានៅតំបន់ណាក៏ដោយ ។ ការរុះរើអាចធ្វើទៅបាន លុះត្រាតែរដ្ឋអំណាចផ្តល់សំណងជូនប្រជារាស្ត្រអោយបានសមរម្យ និងយុត្តិធម៌ ។ សំណងនោះអាចជាផ្ទះសំបែងនៅទីកន្លែងណាមួយទៀតមានលក្ខណៈប្រហាក់ប្រហែលផ្ទះសំបែងដើម ឬជាថវិកាមានចំនួនប្រហាក់ប្រហែលតម្លៃផ្ទះសំបែងដើម ។

_រដ្ឋអំណាចនឹងរៀបចំលំនៅដ្ឋានសំរាប់ជនក្រីក្រ ដោយសាងសង់អាគារថ្មីនៅលើដីធ្លីរបស់រដ្ឋ ឬជួសជុល និងកែច្នៃអាគាររបស់រដ្ឋដែលមានស្រាប់ ។ លំនៅដ្ឋាននេះស្ថិតក្នុងកម្មវិធីសង្គមកិច្ច ហើយត្រូវដាក់ជួលក្នុងតម្លៃទាប ឬអោយស្នាក់នៅដោយឥតគិតថ្លៃ សំរាប់ជនក្រីក្រជាទីបំផុត ។

_ហាមឃាត់មិនអោយមានសិទ្ធិផ្តាច់មុខ ក្នុងការប្រកបអាជីវកម្មផលិត និងចែកចាយអគ្គីសនី ។ នៅគ្រប់តំបន់ទាំងអស់ ប្រជាពលរដ្ឋមានសិទ្ធិរៀបចំជាសមាគម ដើម្បីផលិត និងចែកចាយអគ្គិសនី ។ បើអគ្គិសនីត្រូវបានផលិតដោយក្រុមហ៊ុនឯកជនណាមួយ តម្លៃអគ្គិសនីដែលដាក់លក់ជូនប្រជាពលរដ្ឋ មិនអាចលើសពីកំរិតមួយដែលកំណត់តាមការពិភាក្សាជាមួយអាជ្ញាធរមានសមត្ថកិច្ច និងតំណាងប្រជាពលរដ្ឋឡើយ ។

_បញ្ចុះតម្លៃប្រេងសាំង និងប្រេងឥន្ធនៈ ផ្សេងទៀត ធ្វើយ៉ាងណាមិនឲ្យមានកំរិតខ្ពស់ជាងនៅប្រទេសជិតខាង មានប្រទេសថៃជាដើម ។ វិធានការនេះជួយដល់ជីវភាពប្រជារាស្ត្រផង និងជួយលុបបំបាត់ការរត់ពន្ធខុសច្បាប់ផង ។

_លុបបំបាត់ការតំរូវអោយបង់ប្រាក់អោយក្រុមហ៊ុនឯកជន ក្នុងការប្រើប្រាស់ផ្លូវជាតិ និងផ្លូវថ្នល់នៅគ្រប់រាជធានី-ខេត្ត និងគ្រប់តំបន់។ឧទាហរណ៏ : ផ្លូវជាតិលេខ៤ ពីរាជធានីភ្នំពេញ ទៅខេត្តព្រះសីហនុ ។

_ផ្តល់ជូនប្រជាពលរដ្ឋជាបន្ទាន់ដោយឥតគិតថ្លៃ នូវឯកសារផ្លូវការសំរាប់ការរស់នៅរាល់ថ្ងៃ ដូចជាអត្តសញ្ញាណប័ណ្ណ សៀវភៅគ្រួសារ ប័ណ្ណស្នាក់នៅ និងលិខិតអនុញ្ញាតផ្សេងៗ ។

_រៀបចំប្រព័ន្ធសន្តិសុខសង្គមទូទាំងប្រទេស ដែលមានបំណងផ្តល់លទ្ធភាពអោយប្រជាពលរដ្ឋគ្រប់រូបទប់ទល់រាល់ចំណាយចាំបាច់ទៅលើការថែទាំសុខភាព និងរក្សាសមត្ថភាពក្នុងការប្រកបការងារចិញ្ចឹមជីវិត ។

_ផ្តល់ការព្យាបាលជំងឺតាមលក្ខណៈវេជ្ជសាស្ត្រ (ពិនិត្យដោយគ្រូពេទ្យ និងផ្តល់ថ្នាំពេទ្យទំនើប) ចំពោះប្រជាពលរដ្ឋក្រីក្រគ្រប់រូបដោយមិនគិតថ្លៃ ។

_ចែកចាយដល់រាល់សិស្សសាលា និងកូនក្មេងក្នុងគ្រួសារក្រីក្រ នូវចំណីអាហារបន្ថែម ដែលមានជីវជាតិ និងធាតុផ្សេងទៀត ចាំបាច់សំរាប់ការលូតលាស់របស់រាងកាយ និងខួរក្បាល និងសំរាប់រក្សាសុខភាពអោយបានល្អជាទូទៅ ។

_ផ្តល់លំនៅដ្ឋាន និងការឧបត្ថម្ភដល់ជនពិការ ដើម្បីធានាជីវភាពនៃជនពិការទាំងអស់អោយបានសមរម្យ និងថ្លៃថ្នូរ ។

***2_ ប្រជាកសិករ***

_ផ្តល់ប្លង់ដី និងប័ណ្ណកម្មសិទ្ធិដោយឥតគិតថ្លៃ ជូនប្រជាកសិករដែលមិនទាន់មានឯកសារទាំងនេះ ដើម្បីបញ្ជាក់ និងការពារកម្មសិទ្ធិលើដីធ្លី ដែលប្រជាកសិករទាំងនោះកំពុងតែគ្រប់គ្រង ដើម្បីចិញ្ចឹមជីវិត ។ មិនយកពន្ធលើដីធ្លីរបស់ប្រជាកសិករ ។

_កសាង ពង្រីង ឬស្តារឡើងវិញ ប្រព័ន្ធធារាសាស្ត្រ (ប្រឡាយទឹក ទំនប់ទឹក ស្រះ ទ្វារទឹក ។ល។) ដើម្បីធានាអោយប្រជាកសិករមានទឹកគ្រប់គ្រាន់ធ្វើស្រែចំការក្នុងរដូវប្រាំង និងរដូវវស្សា ។

_រកទីផ្សារជូនប្រជាកសិករ ដើម្បីលក់ផលដំណាំ ដូចជា ស្រូវ ពោត សណ្តែក ល្ង ថ្នាំជក់ ស្ករត្នោត ជ័រកៅស៊ូ ។ល។ ក្នុងតំលៃខ្ពស់សមរម្យ ដែលធ្វើអោយជីវភាពអ្នកធ្វើស្រែចំការបានធូរធារ ។ ក្នុងគោលដៅនេះ ត្រូវតែ :

+ ផ្តល់សេរីភាពពេញលេញជូនអ្នកលក់ដូរ
+ លុបបំបាត់សិទ្ធិផ្តាច់មុខ ឬលុបបាត់ការបង្ខំអោយលក់កសិផលក្នុងតំលៃទាប
+ កាត់បន្ថយឥទ្ធិពលឈ្មួញកណ្តាល
+ រៀបចំផ្លូវថ្នល់ និងមធ្យោបាយដឹកជញ្ជូនអោយបានល្អប្រសើរ
+ រៀបចំប្រព័ន្ធសេរីប្រមូលកសិផលដើម្បីការពារផលប្រយោជន៍កសិករ
+ ផ្តល់ព័ត៌មានជាក់ស្តែងពីតំលៃកសិផលលើទីផ្សារជាតិ និងអន្តរជាតិជូនចំពោះប្រជាកសិករ ។

_ជួយការពារប្រជាកសិករដែលជំពាក់បំណុលអង្គការឥណទាន ហើយដែលគ្មានលទ្ធភាពបង់ការប្រាក់ ឬសងបំណុលដើម តាមការកំណត់ដោយសារហេតុផលណាមួយ ដែលមិនអាចដឹងមុនដូចជា ទឹកជំនន់ ភាពរាំងស្ងួត ជំងឺ ឬគ្រោះថ្នាក់ផ្សេងៗ ។ ជួយរកដំណោះស្រាយជាមួយអង្គការឥណទាន ដោយជៀសវាងមិនអោយមានការរឹបអូសយកដីស្រែ ឬផ្ទះសំបែងរបស់អ្នកជំពាក់បំណុល ។ បំណុលនោះត្រូវពន្យារ ឬកាត់បន្ថយ ។

### *3-ប្រជានេសាទ*

_លុបចោលឡូតិ៍នេសាទពាណិជ្ជកម្មឯកជន ដែលគ្រប់គ្រងដោយនាយទុនធំៗ ។ ប្រជាពលរដ្ឋដែលរស់នៅតាមតំបន់នេសាទមានសិទ្ធិរៀបចំជាសហគមន៍នេសាទ ដើម្បីប្រកបមុខរបរនេសាទក្នុងលក្ខណៈគ្រួសារ ហើយជួយថែរក្សាមច្ឆជាតិ និងសម្បត្តិធម្មជាតិដទៃទៀត ។ ការរៀបចំជាសហគមន៍នេសាទនេះ ត្រូវធ្វើឡើងដោយការបោះឆ្នោតត្រឹមត្រូវ ពីព្រោះលទ្ធិប្រជាធិបតេយ្យ និងការរីកចំរើននៃជីវភាពរបស់អ្នកនេសាទតូចតាច តំរូវអោយប្រជារាស្ត្រមានសិទ្ធិគ្រប់គ្រងដោយខ្លួនឯងនូវតំបន់នេសាទ ក្រោមការមើលខុសត្រូវរបស់អាជ្ញាធរមានសមត្ថកិច្ច ។

### *៤-មន្ត្រីរាជការ គ្រូបង្រៀន ប៉ូលីស-ទាហាន*

_តំលើងប្រាក់ខែជូនមន្ត្រីរាជការគ្រប់រូបអោយបានយ៉ាងតិច ៦០ម៉ឺនរៀល (ឬ១៥០ដុល្លារ) ។ ប្រាក់បៀវត្សនេះត្រូវបើកអោយបានទៀងទាត់រៀងរាល់ខែ ។

_លើកទឹកចិត្តគ្រូពេទ្យ និងគ្រូបង្រៀនដែលស្ម័គ្រចិត្តទៅធ្វើការនៅតំបន់ដាច់ស្រយាល ដោយផ្តល់ប្រាក់កំរៃពិសេសបន្ថែមលើប្រាក់ខែធម្មតា ។ វិធានការនេះមានបំណងជួយថែទាំសុខភាពប្រជារាស្ត្រ និងជួយកូនចៅអ្នកស្រែចំការ អោយបានរៀនសូត្រដូចកូនចៅអ្នកទីក្រុង ។

### *៥-កម្មករ និងនិយោជិត*

_ជំរុញអោយសេដ្ឋកិច្ចលូតលាស់ ដើម្បីបង្កើតការងារសំរាប់យុវជន ដែលដល់អាយុរកការងារធ្វើចំនួនប្រមាណ ៣០ម៉ឺននាក់ក្នុងមួយឆ្នាំ ។ ការបង្កើតការងារនេះអាស្រ័យលើការលើកទឹកចិត្តអ្នកវិនិយោគខ្មែរ និងបរទេសអោយបង្កើត សហគ្រាស រោងចក្រ និងសកម្មភាពផ្សេងៗ ដើម្បីស្រូបយកពលករដែលនៅទំនេរ អោយបានចូលធ្វើការគ្រប់គ្នា ។ វិនិយោគ នឹងកើនឡើង ក្រោយពីយើងបំបាត់អំពើពុករលួយ និងបង្កលក្ខណៈងាយស្រួលដល់ការប្រកបអាជីវកម្មស្របច្បាប់ ។ ក្នុងគោលបំណងនេះ យើងត្រូវធានាជូនអ្នកវិនិយោគនូវ :

+ សន្តិសុខរាងកាយ
+ សន្តិសុខផ្លូវច្បាប់ (ដូចជាការគោរពកិច្ចសន្យា)
+ ការរៀបចំអោយមានតុលាការឯករាជ្យ និងយុត្តិធម៌)
+ ការកសាងហេដ្ឋារចនាសម្ព័ន្ធ (ផ្លូវថ្នល់ ទឹក ភ្លើង ទូរស័ព្ទ ។ល។) អោយមានភាពទំនើប

+ ការបណ្តុះបណ្តាលពលករតាមសេចក្តីត្រូវការរបស់អ្នកវិនិយោគ ។

_តំលើងប្រាក់ខែជូនកម្មកររោងចក្រ និងបុគ្គលិកក្រុមហ៊ុនអោយបានយ៉ាងតិច ៤០ម៉ឺនរៀល ទៅ៦០ម៉ឺនរៀល (ឬ១០០ដុល្លារ ទៅ១៥០ដុល្លារ) ដោយធ្វើការតែ ៤៤ ម៉ោងក្នុងមួយសប្តាហ៍ ។ ម៉ោងពេលធ្វើការលើសពីនេះ ត្រូវគិតតាមតម្លៃថែមម៉ោង យោងតាមច្បាប់ការងារ ។

_ជំរុញអោយបង្កើតតុលាការការងារអោយបានឆាប់រហ័ស ដូចមានចែងក្នុងច្បាប់ការងារ ដើម្បីដោះស្រាយវិវាទរវាងនិយោជិត និងនិយោជក ។ ក្នុងពេលឥឡូវនេះត្រូវធានាអោយក្រុមប្រឹក្សាអាជ្ញាកណ្តាលមានភាពឯករាជ្យ ដើម្បីដោះស្រាយវិវាទការងាររវាងកម្មករ និងថៅកែរោងចក្រ ប្រកបដោយប្រសិទ្ធភាព និងយុត្តិធម៌) ។

### ៦-អាជីវករ និងអ្នកលក់ដូរតូចតាច

_បញ្ឈប់ការបណ្តេញ ឬការបង្ខំអោយរុះរើតូបរបស់អ្នកលក់ដូរតូចតាចនៅតាមទីផ្សារគ្រប់ខេត្ត-ក្រុង ។ ការសាងសង់អាគារថ្មី ដើម្បីជំនួសទីផ្សារសព្វថ្ងៃ អាចធ្វើទៅបានលុះត្រាតែមានការយល់ព្រមពីអ្នកលក់ដូរសព្វថ្ងៃ នៅតាមទីផ្សារនីមួយៗ ។ ការយល់ព្រមនេះត្រូវផ្អែកលើលក្ខណៈបច្ចេកទេសនៃអាគារថ្មី ដែលគ្រោងសាងសង់ ព្រមទាំងលើតម្លៃនៃរាន ឬតូបដែលគ្រោងដាក់លក់ ឬជួល នៅក្នុងអាគារថ្មី ។ ត្រូវបញ្ចុះពន្ធដារ និងភាស៊ីផ្សារ ដែលប្រមូលពីអ្នកលក់ដូរតូចតាច ។

### ៧-អ្នករត់ម៉ូតូឌុប និងតាក់ស៊ី

_លុបបំបាត់ពន្ធដារ និងការជំរិតទារប្រាក់គ្រប់ប្រភេទ ពីអ្នករត់តាក់ស៊ី អ្នករត់រ៉ឺម៉ក អ្នកបររទេះ និងអ្នករត់ម៉ូតូឌុបនៅទូទាំងប្រទេស ។

### ៨-សិស្ស និងនិស្សិត

_ធានាអោយកូនខ្មែរគ្រប់រូបបានចូលរៀនគ្រប់ម៉ោងពេល ក្នុងប្រព័ន្ធអប់រំរបស់រដ្ឋ ពីបឋមសិក្សា ដល់មធ្យមសិក្សា ដោយមិនចាំបាច់បង់ថ្លៃ ។

_រៀបចំសាងសង់ និងគ្រប់គ្រងបុរីនិស្សិត នៅតាមទីក្រុងដែលមានមហាវិទ្យាល័យ ដើម្បីជាកន្លែងស្នាក់នៅដោយគិតថ្លៃជួលទាបបំផុត សំរាប់និស្សិតដែលមកពីជនបទ ។

_រៀបចំប្រព័ន្ធអាហារូបករណ៍ (ការឧបត្ថម្ភដល់សិស្ស និងនិស្សិត) សំរាប់ជួយសិស្ស និងនិស្សិតមកពីគ្រួសារក្រីក្រ ដែលមានសមត្ថភាពសិក្សាបានវែងឆ្ងាយ អោយមានលទ្ធភាពបំពេញការសិក្សាដល់កំរិតខ្ពស់ជាអតិបរមា ។

_បង្កើនលទ្ធភាពអោយនិស្សិតខ្មែរ បានទៅសិក្សានៅបរទេសគ្រប់មុខជំនាញរយៈពេលយូរឆ្នាំ ។ ចរចាជាមួយប្រទេសម្ចាស់ជំនួយអោយផ្ទេរជំនួយមួយផ្នែកសំរាប់ប្រើប្រាស់ ក្នុងការរៀបចំកម្មវិធីបញ្ជូននិស្សិតខ្មែរ ទៅសិក្សានៅបស្ចិមប្រទេស ។

**-បោះឆ្នោតឱ្យគណបក្ស សម រង្ស៊ី ដើម្បីការពារបូរណភាពទឹកដីខ្មែរឱ្យបានគង់វង្ស**

**-បោះឆ្នោតឱ្យគណបក្ស សម រង្ស៊ី ដើម្បីលើកតម្កើងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ**

២

**គណបក្ស សម រង្ស៊ី**

**គ.ស.រ.**

✓

# គណបក្ស សម រង្ស៊ី

## SAM RAINSY PARTY
## PARTI SAM RAINSY

**សីលធម៌ សច្ចធម៌ យុត្តិធម៌**

## សេចក្ដីសម្រេចសមាជគណបក្ស សម រង្ស៊ី លើកទី៥
## ធ្វើឡើងនៅទីក្រុងភ្នំពេញ ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១១




*សមាជិកនៃសមាជគណបក្សលើកទី៥ លើកដៃអនុម័តសេចក្ដីសម្រេច*

សមាជគណបក្ស សម រង្ស៊ី លើកទី៥ ដែលបានធ្វើឡើងនៅរាជធានីភ្នំពេញ ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១១ ដោយមានការចូលរួមពីប្រតិភូប្រមាណ ៥០០០នាក់ តំណាងអោយគ្រប់ខេត្ត-ក្រុងនៃប្រទេសកម្ពុជា ព្រមទាំងសហគមន៍ខ្មែរនៅឯនាយសមុទ្រផងដែរ បានអនុម័តនូវសេចក្ដីសំរេចដូចតទៅ :

១_អំពាវនាវដល់កម្លាំងស្នេហាជាតិទាំងអស់ឲ្យរួបរួមគ្នា ដើម្បីបញ្ចៀសប្រទេសកម្ពុជាពីមហន្តរាយ ។ បញ្ឈប់នយោបាយរាជរដ្ឋាភិបាលបច្ចុប្បន្នដែលកំពុងតែពុះច្រៀកប្រទេសកម្ពុជា ដើម្បីកាត់ទឹកដីខ្មែរជាដុំៗទៅលក់ឲ្យក្រុមហ៊ុនបរទេស ក្រោមរូបភាព "សម្បទាន" ។ ប្រឆាំងការប៉ុនប៉ងសម្លាប់ជនជាតិខ្មែរបន្តិចម្ដងៗ ដោយធ្វើឲ្យកសិកររបស់យើងអស់ដី អស់ព្រៃ អស់ត្រី ។ ជំទាស់ផែនការខ្មៅងងឹតដែលជម្រុញឲ្យប្រទេសកម្ពុជាហិនហោច និងលិចលង់ដោយការបាត់បង់ទឹកដី ការរឹបអូសយកដីធ្លី ការកាប់បំផ្លាញព្រៃឈើ ការបំផ្លាញមច្ឆាជាតិ ការលួចប្លន់ទ្រព្យសម្បត្តិធម្មជាតិ អំពើពុករលួយជាប្រព័ន្ធគ្រប់គ្រងប្រទេស ភាពក្រីក្រកាន់តែធ្ងន់ធ្ងរទៅៗ ការមិនមានការងារធ្វើ ភាពរយីករយៀកនៃសេវាសាធារណៈ ដូចជាប្រព័ន្ធសុខាភិបាល ភាពអស់សង្ឃឹម ការចាកចេញពីប្រទេសនៃប្រជាពលរដ្ឋខ្មែរកាន់តែច្រើនឡើងៗ ដែលត្រូវបង្ខំខ្លួនទៅរកការងារធ្វើនៅឯបរទេស ការហូរចូលក្នុងប្រទេសយើងនៃជនអន្តោប្រវេសន៍យួនកាន់តែច្រើនឡើងៗ ដែលទំនងធ្វើឲ្យប្រទេសកម្ពុជាក្លាយទៅជាកម្ពុជាក្រោមមួយទៀត ។



*សម្រែកដីឈឺចាប់របស់ប្រជាពលរដ្ឋតំបន់បឹងកក់ ភ្នំពេញ*

២_គាំទ្រ និងផ្សព្វផ្សាយពាក្យស្លោកគណបក្ស សម រង្ស៊ី : "ប្រគល់សងប្រជារាស្ត្រវិញ ទ្រព្យសម្បត្តិដែលត្រូវបានលួចប្លន់ដោយអ្នកដទៃ" ។ ប្រជារាស្ត្រជាម្ចាស់ទឹកម្ចាស់ដីតែមួយគត់ ។ រដ្ឋាភិបាលអនាគតដឹកនាំដោយគណបក្ស សម រង្ស៊ី នឹងលុបចោលរាល់សម្បទានដីធ្លី សម្បទានព្រៃឈើ និងសម្បទានរ៉ែ ដែលបានផ្ដល់ឲ្យក្រុមហ៊ុនឯកជនដោយរដ្ឋាភិបាលបច្ចុប្បន្ន ដោយការរឹបអូសយកដីធ្លី និងការបណ្ដេញម្ចាស់ដើម និងអ្នកគ្រប់គ្រងដីធ្លីទាំងនោះតាំងពីដើមទី ។ ទ្រព្យសម្បត្តិជាតិនឹងប្រគល់សងប្រទេសជាតិវិញ ។ ដីធ្លី ស្រែចំការ ព្រៃឈើ ព្រៃភ្នំ ស្ទឹង បឹង ទន្លេ តំបន់នេសាទ ឆ្នេរសមុទ្រ និងកោះ នឹងត្រូវប្រគល់សងម្ចាស់ដើមម្ចាស់ពិតវិញ គឺប្រជារាស្ត្រខ្មែរ ឬក៏ត្រូវយកទៅគ្រប់គ្រងដើម្បីបំរើផលប្រយោជន៍សាធារណៈ នឹងឆ្លើយតបនឹងសេចក្ដីត្រូវការរបស់ប្រជាពលរដ្ឋទូទៅ ។ បុគ្គលណា ឬក្រុមហ៊ុនឯកជនណាដែលបានដណ្ដើមយកដីធ្លី និងតំបន់ដែលប្រជារាស្ត្ររស់នៅដោយប្រើអំពើហិង្សា ត្រូវចាត់ទុកជាសត្រូវនៃប្រជារាស្ត្រខ្មែរ នឹងត្រូវផ្ដន្ទាទោសជាពុំខាន ។ ប្រជារាស្ត្រខ្មែរនឹងក្លាយទៅជាម្ចាស់ទឹកម្ចាស់ដីតែមួយគត់ ។



*កសិករឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ បិទផ្លូវជាតិលេខ៤ ដើម្បីឲ្យអាជ្ញាធរដោះស្រាយសំណូមពររបស់ពួកគាត់*

៣_គាំទ្រសេចក្តីអំពាវនាវនៃគណបក្ស សម រង្ស៊ី ដល់អ្នកវិនិយោគបរទេសសុច្ចរិត ឲ្យមកបណ្តាក់ទុននៅប្រទេសកម្ពុជា ដើម្បីសាងសង់រោងចក្រកែច្នៃវត្ថុធាតុដើម ដែលត្រូវទិញពីកសិករយើង តែមិនត្រូវដណ្តើមដីធ្លីពីកសិករយើងទេ ។ អ្នកវិនិយោគទុនដែលប្រទេសកម្ពុជាត្រូវការ មិនចូលរួមក្នុងការជួញដូរដីធ្លីទេ ហើយក៏មិនមកប្រទេសយើង ដើម្បីលាងលុយកខ្វក់ដែរ ។ អ្នកវិនិយោគត្រឹមត្រូវ គឺខិតខំសាងសង់រោងចក្រកែច្នៃវត្ថុធាតុដើមដែលផ្តល់ទីផ្សារ ឲ្យផលិតកម្មនៃកសិករខ្មែរ និងផ្តល់ការងារធ្វើឲ្យប្រជាពលរដ្ឋទូទៅ ។

៤_ជំទាស់ និងប្រឆាំងចោលរបៀប "អភិវឌ្ឍន៍" រៀបចំដោយរដ្ឋាភិបាលបច្ចុប្បន្នដែលជាការអភិវឌ្ឍន៍ក្លែងក្លាយ ប្រឆាំងប្រជារាស្ត្រ ហើយបំរើផលប្រយោជន៍តែជនមួយក្តាប់តូចតែប៉ុណ្ណោះ ដែលកេងប្រវ័ញ្ចញើសឈាមប្រជារាស្ត្រ ។ រដ្ឋាភិបាលអនាគតដឹកនាំដោយគណបក្ស សម រង្ស៊ី នឹងរៀបចំប្រទេសឲ្យមានការអភិវឌ្ឍន៍ពិតប្រាកដសម្រាប់ប្រជារាស្ត្រ ដែលការពារទ្រព្យសម្បត្តិប្រជារាស្ត្រ បំរើផលប្រយោជន៍ប្រជារាស្ត្រ និងធ្វើឲ្យមានការរីកចំរើនពិតប្រាកដចំពោះជីវភាពរស់នៅរបស់ប្រជារាស្ត្រ ។

៥_ថ្កោលទោសនយោបាយប្រជាភិថុតនៃគណបក្សកាន់អំណាចសព្វថ្ងៃ ដែលម្ខាងចែកអំណោយបន្តិចបន្តួច ម្តងម្កាលដើម្បីទិញសន្លឹកឆ្នោត តែម្ខាងទៀតច្របាច់កយើងជាប្រចាំ ដោយបន្ទៀបប្រាក់ខែកម្មករ និងមន្ត្រីរាជការ តំឡើងពន្ធកាន់តែធ្ងន់ទៅៗ ហើយធ្វើឲ្យទំនិញឡើងថ្លៃឥតឈប់ឈរនៅលើទីផ្សារ ។ គេលួចជាតិនិងលក់ជាតិបានរាប់ម៉ឺនរាប់សែនតាមរយៈអំពើពុករលួយ តែគេឲ្យយើងវិញមួយកាក់មួយសេនជាអំណោយបោកបញ្ឆោត ។

៦_ទាមទារឲ្យតំឡើងប្រាក់ខែកម្មករ និងមន្ត្រីរាជការ ជាបន្ទាន់ និងជាគួរឲ្យកត់សំគាល់ដើម្បីធានាជីវភាពសមរម្យសម្រាប់កម្មករ និងមន្ត្រីរាជការទាំងនោះ និងទាមទារឲ្យមានការចាត់វិធានការជាក់ស្តែង ដើម្បីធ្វើឲ្យទំនិញចុះថ្លៃនៅលើទីផ្សារ ដោយបញ្ចុះពន្ធដារ ហើយបញ្ឈប់សិទ្ធិផ្តាច់មុខដែលអនុញ្ញាតឲ្យឈ្មួញទុច្ចរិតធ្វើភៀងធ្វើផ្ការតាមតែអំពើចិត្តលើទីផ្សារ ។

៧_យល់ព្រម និងគាំទ្រផែនការសកម្មភាពនៃគណបក្ស សម រង្ស៊ី ដើម្បីធ្វើឲ្យជីវភាពប្រជាពលរដ្ឋល្អប្រសើរឡើង នៅលើបីវិស័យ: កសិកម្ម ការងារ និងសុខាភិបាល ។ វិធានការជាក់ស្តែងដែលមានក្នុងផែនការនេះនឹងបង្កើនប្រាក់ចំណូល ហើយលើកស្ទួយជីវភាពរបស់កសិករ បង្កើតការងារឲ្យប្រជាពលរដ្ឋទូទៅ ជាពិសេសយុវជន ហើយផ្តល់ការព្យាបាលជម្ងឺត្រឹមត្រូវដល់ប្រជាពលរដ្ឋទូទៅ ជាពិសេសអ្នកក្រីក្រជាងគេ ។

៨_យល់ព្រម និងគាំទ្រសេចក្តីស្នើច្បាប់របស់តំណាងរាស្ត្រគណបក្ស សម រង្ស៊ី ទាក់ទងទៅនឹង :

_ការកំណត់ប្រាក់ខែអប្បបរិមា (តិចបំផុត) សម្រាប់រាល់មុខរបរទូទាំងប្រទេស ។ ប្រាក់ខែអប្បបរិមានេះត្រូវកំណត់បីខែម្តង យោងការវិវត្តន៍នៃតំលៃទំនិញលើទីផ្សារ ។ ពេលឥឡូវនេះ ប្រាក់ខែអប្បបរិមាមិនអាច តិចជាង ៤០ម៉ឺនរៀលបានទេ ។

_ការកំណត់ធម្មនុញ្ញនៃសិទ្ធិរបស់អ្នកជួលផ្ទះគេ ដើម្បីធានាស្ថេរភាពលំនៅដ្ឋានសម្រាប់សាមីខ្លួន ដោយលក្ខខណ្ឌសមរម្យ អាចទទួលយកបាន ព្រមទាំងធានាសំណងសមរម្យ និងយុត្តិធម៌សម្រាប់សាមីខ្លួន ក្នុងករណីម្ចាស់ផ្ទះ ឬអាជ្ញាធរសាធារណៈត្រូវបញ្ចប់កិច្ចសន្យាជួលផ្ទះ ។

_ការរៀបចំប្រទេសឲ្យមានវិមជ្ឈការពិតប្រាកដដែលផ្តល់សិទ្ធិជាក់ស្តែង និងថវិកាគ្រប់គ្រាន់ អនុញ្ញាតឲ្យក្រុមប្រឹក្សាឃុំ-សង្កាត់អាចចាត់ និងអនុវត្តវិធានការតាមបែបបទប្រជាធិបតេយ្យ ដែលទាក់ទងទៅនឹងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតាមឃុំ-សង្កាត់នីមួយៗ ដូចជាសេចក្តីសំរេចទាក់ទងទៅនឹងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន សេវាសង្គមកិច្ច និងការការពារបរិស្ថាន ។

_ការកំណត់អាណត្តិសម្រាប់នាយករដ្ឋមន្ត្រីម្នាក់ៗ ឲ្យបំពេញមុខងាររបស់ខ្លួនបានតែមួយអាណត្តិរយៈពេលប្រាំឆ្នាំតែប៉ុណ្ណោះ ។

៩_យល់ព្រម និងគាំទ្រយុទ្ធសាស្ត្រនយោបាយគណបក្ស សម រង្ស៊ី ជាបីដំណាក់កាល ដើម្បីរំដោះប្រទេសកម្ពុជា ពីការត្រួតត្រារបស់បរទេស បញ្ចប់អំណាចផ្តាច់ការ បោសសំអាតអំពើពុករលួយ និងធានាយុត្តិធម៌សង្គម ។ ដំណាក់កាលទាំងបីនោះមាន :

_ការចូលរួមក្នុងការបោះឆ្នោតនៅឆ្នាំ២០១២ និង២០១៣ ដោយខិតខំទប់ស្កាត់ភាពមិនប្រក្រតី និងភាពអយុត្តិធម៌តាមសមត្ថភាពរបស់យើង ។

_ការលើកទឹកចិត្តប្រជាពលរដ្ឋឲ្យងើបឈរប្រឆាំងអំណាចផ្តាច់ការ តាមការតវ៉ាគ្រប់បែបយ៉ាង ដោយសន្តិវិធី និងអហិង្សា ដូចនៅក្នុងប្រទេសអារ៉ាប់មួយចំនួននៅឆ្នាំ២០១១នេះ បើការបោះឆ្នោតខាងមុខនេះមិនយុត្តិធម៌ ហើយនៅតែបំភ្លៃឆន្ទៈប្រជារាស្ត្រដូចមុនទៀត ។

_ការដាក់ពាក្យបណ្តឹង ប្តឹងអ្នកដឹកនាំជាជនឧក្រិដ្ឋ នៅចំពោះមុខតុលាការអន្តរជាតិ និងតុលាការឯករាជ្យនៅក្នុងប្រទេសប្រជាធិបតេយ្យក្នុងពិភពលោក ដើម្បីឲ្យមានការចាប់អ្នកដឹកនាំជាជនឧក្រិដ្ឋទាំងនោះ យកទៅផ្តន្ទាទោសតាមច្បាប់ ។

១០_ទាមទារយុត្តិធម៌ឲ្យលោកប្រធាន សម រង្ស៊ី ដែលបានការពារដីស្រែកសិករខ្មែរនៅតាមដងព្រំប្រទល់ដែនជាមួយប្រទេសវៀតណាម ។ ដីធ្លីរបស់ជនជាតិខ្មែរទាំងនោះ គឺជាទឹកដីនៃប្រទេសកម្ពុជារបស់យើងទាំងអស់គ្នា ។ ដូច្នេះករណីលោកប្រធាន សម រង្ស៊ី មិនមែនជារឿងផ្ទាល់ខ្លួនទេ គឺជាបញ្ហាជាតិដែលតម្រូវឲ្យមានដំណោះស្រាយនយោបាយ ។ យើងទាមទារឲ្យមានការយកចិត្តទុកដាក់ចំពោះអនុសាសន៍មកពីតំណាងនៃអង្គការសហប្រជាជាតិ សហភាពអន្តរសភា សភាអឺរ៉ុប និងរដ្ឋាភិបាលនៃប្រទេសជាមិត្តជាច្រើន ដែលចង់ឃើញលោកប្រធាន សម រង្ស៊ី វិលត្រឡប់មកវិញ ដើម្បីចូលរួមការបោះឆ្នោតឆ្នាំ២០១២ និង២០១៣ ។ បើគ្មានការចូលរួមពីប្រធានគណបក្សប្រឆាំងដ៏ធំជាងគេនោះទេ ការបោះឆ្នោតខាងមុខនេះនឹងមិនមានតំលៃទេ ហើយសហគមន៍អន្តរជាតិក៏មិនទទួលស្គាល់លទ្ធផលនៃការបោះឆ្នោតបែបនេះទេ ដូចជាគេមិនទទួលស្គាល់រដ្ឋាភិបាលណាដែលចេញមកពីការបោះឆ្នោតរបៀបនេះដែរ ។

១១_អំពាវនាវឲ្យប្រជាពលរដ្ឋទាំងអស់ទៅផ្ទៀងផ្ទាត់ឈ្មោះ និងចុះឈ្មោះលើបញ្ជីឈ្មោះបោះឆ្នោត ឲ្យបានមុនថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១១ ដើម្បីអាចចូលរួមក្នុងការបោះឆ្នោតឆ្នាំ២០១២ និង២០១៣ ដែលសម្រេចវាសនាប្រទេសជាតិយើង ព្រមទាំងអនាគតយើងម្នាក់ៗ ព្រមទាំងកូនចៅយើង ។

១២_ស្នើសុំឲ្យប្រទេសជាហត្ថលេខីទាំងអស់នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ស្តីពីកម្ពុជា ឆ្នាំ១៩៩១ អនុវត្តកិច្ចព្រមព្រៀងទាំងនោះឲ្យបានត្រឹមត្រូវ និងពេញលេញ ក្នុងឱកាសខួបទី២០ នៃការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ នៅថ្ងៃទី២៣ ខែតុលា ខាងមុខនេះ ។ កិច្ចព្រមព្រៀងនេះធានាជូនប្រជារាស្ត្រខ្មែរ នូវសិទ្ធិសេរីភាពជាមូលដ្ឋាន ព្រមទាំងប្រព័ន្ធប្រជាធិបតេយ្យ សេរីពហុបក្ស ដែលសិទ្ធិសេរីភាព និងប្រព័ន្ធប្រជាធិបតេយ្យនេះមានតែនៅលើក្រដាសរហូតមកដល់បច្ចុប្បន្ននេះ ។ កិច្ចព្រមព្រៀងទីក្រុងប៉ារីសក៏បានធានាផងដែរ នូវបូរណភាពទឹកដីនៃប្រទេសកម្ពុជា ដែលមានការរំលោភពីសំណាក់ប្រទេសថៃ និងប្រទេសវៀតណាមមកលើបូរណភាពទឹកដីនៃប្រទេសកម្ពុជា ទាំងខាងលិច ទាំងខាងកើត ដែលប្រជាពលរដ្ឋខ្មែរត្រូវរងគ្រោះទាំងសងខាង ។




_បោះឆ្នោតឱ្យគណបក្ស សម រង្ស៊ី ដើម្បីការពារបូរណភាពទឹកដីខ្មែរឱ្យបានគង់វង្ស
_បោះឆ្នោតឱ្យគណបក្ស សម រង្ស៊ី បញ្ឈប់ការរឹបអូសយកដីធ្លីផ្ទះសម្បែងប្រជាពលរដ្ឋ

០២ គណបក្ស សម រង្ស៊ី
គ.ស.រ. ✓

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ប្រ.ក/លេខ . 12.078/11 គ.ជ.ប/អគ្គ/ព.ស

រាជធានីភ្នំពេញ,ថ្ងៃទី 29 ខែធ្នូ ឆ្នាំ២០១១

# កម្មវិធីផ្សាយគោលនយោបាយគណបក្សតាម

## ទូរទស្សន៍ជាតិកម្ពុជា (ទទក) វិទ្យុជាតិ AM 918 KHz និងវិទ្យុ FM 96 MHz

## ចាប់ពីថ្ងៃទី ០៧ ដល់ថ្ងៃទី ២៧ ខែមករា ឆ្នាំ២០១២

## សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៣

| ពេល | ទូរទស្សន៍ជាតិកម្ពុជា (ទទក) | វិទ្យុជាតិ AM (918) KHz | វិទ្យុ FM 96 MHz |
|---|---|---|---|
| ព្រឹក | | 7:00h – 8:00h | |
| រសៀល | 13:30h – 14:30h | | 13:00h – 14:00h |
| យប់ | 20:30h – 21:30h | 20:00h – 21:00h | 22:00h – 23:00h |

ព័ត៌មានបន្ថែមទំនាក់ទំនង : 023 214 374 / 012 855 018 ; E-mail: necinfo@forum.org.kh; www.necelect.org.kh